


# ភូមិតាណារ៍មុន និងអំឡុងពេលខ្មែរក្រហមចូលមកគ្រប់គ្រង

អត្ថបទស្រាវជ្រាវខ្លីដោយ ៖ សោម ប៊ុនថន

# មាតិកា


សង្ខេបអត្ថបទ

សេចក្តីផ្តើម

១) ស្ថានភាពទូទៅ

ទីតាំងភូមិសាស្ត្រ

មុខរបរ

សាលារៀន

សេវាព្យាបាលជំងឺ

ការប្រតិបត្តិជំនឿ សាសនា

២) រដ្ឋប្រហារ

ដើមដំបូងនៃរបប លន់ នល់

ការបង្កើតទីតាំងយោធា

ការជ្រៀតចូលរបស់កងទ័ពវៀតកុង

ការវាយប្រយុទ្ធ និងការរត់ចោលជួរ

៣) ការមកដល់នៃរបបខ្មែរក្រហម

ជម្លៀសលើកដំបូង

ការបែងចែករចនាសម្ព័ន្ធគ្រប់គ្រងថ្មី

ការស៊ើបរកខ្មាំង

ការបង្កើតមន្ទីរសន្តិសុខ

ការវិលត្រលប់មកភូមិកំណើត

សន្និដ្ឋាន

សង្ខេបអត្ថបទ

អត្ថបទស្រាវជ្រាវខ្លីនេះ នឹងធ្វើការសិក្សាដោយផ្តោតសំខាន់ទៅលើស្ថានភាពរស់នៅរបស់ប្រជាជនក្នុងភូមិតាណវ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលចាប់ពីឆ្នាំ១៩៧០ រហូតដល់របបខ្មែរក្រហមគ្រប់គ្រង និងការបង្កើតមន្ទីរសន្តិសុខក្នុងភូមិតាណវ៍។ អត្ថបទនេះក៏បានឆ្លើយតបនឹងសំណួរមួយចំនួន ដូចជា តើស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិតាណវ៍ក្នុងអំឡុងពេលរដ្ឋប្រហារ និងអំឡុងសង្គ្រាមឆ្នាំ១៩៧០ ជួបប្រទះបញ្ហាអ្វីខ្លះ? តើខ្មែរក្រហមជម្លៀសប្រជាជនក្នុងភូមិតាណវ៍ទៅតំបន់ណាខ្លះ? តើខ្មែរក្រហមរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងភូមិតាណវ៍របៀបណា? នៅក្នុងការសរសេរអត្ថបទស្រាវជ្រាវខ្លីនេះ ខ្ញុំបានធ្វើការសម្ភាសន៍ជាមួយមនុស្សប្រាំមួយនាក់ រួមមាន អតីតទាហាន លន់ នល់ ពីរនាក់ គ្រូបង្រៀនម្នាក់ មេភូមិម្នាក់ និងប្រជាជនពីរនាក់។ បន្ថែមលើបទសម្ភាសន៍ ខ្ញុំបានដកស្រង់ចេញពីរបាយការណ៍ផែនទីរណ្តៅសាកសព ឆ្នាំ១៩៩៥ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា, អត្ថបទបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីស្វែងរកការពិត, គម្រោងផ្សព្វផ្សាយអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៥, របាយការណ៍វិភាគអំពីសកម្មភាពយោធា នៅក្នុងខេត្តស្វាយរៀង ដែលចេញផ្សាយដោយស៊ីអាយអេ និងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

សេចក្តីផ្តើម

តាំងពីសម័យបារាំង ប្រជាជននៅក្នុងភូមិតាណវ៍ បានពឹងផ្អែកសំខាន់ទៅលើរបរកសិកម្ម ដូចជា ចិញ្ចឹមគោ-ក្របី ជ្រូក មាន់ទា ធ្វើស្រែ ដាំបន្លែ ធ្វើស្ករត្នោត និងរកត្រី ព្រោះភូមិនេះមានទីតាំងជាប់ដៃទន្លេវ៉ៃគោបែកខាងត្បូង ភ្ជាប់ទៅប្រទេសវៀតណាម។ ពីមួយឆ្នាំទៅមួយឆ្នាំ របរទាំងនេះមិនបានជួយឱ្យជីវភាពរបស់ប្រជាជននៅក្នុងភូមិតាណវ៍មានជីវភាពធូរធារឡើយ ទោះបីយ៉ាងណា របរទាំងអស់នេះធ្វើឱ្យប្រជាជននៅក្នុងភូមិបានរស់នៅជួបជុំគ្នាប្រកបដោយសេចក្តីរីករាយ និងសុភមង្គល។ នៅក្នុងអំឡុងសម័យសង្គ្រាមវៀតណាមក្នុងទសវត្សរ៍ឆ្នាំ៦០ និង៧០ ខេត្តស្វាយរៀង ដែលស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា និងមានព្រំប្រទល់ជាប់នឹងវៀតណាមខាងត្បូង ដែលមានឈ្មោះជាផ្លូវការថា សាធារណរដ្ឋវៀតណាម[1] បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការទម្លាក់គ្រាប់បែកនៅតាមបណ្តោយព្រំដែន ជាពិសេសប្រជាជនដែលរស់នៅក្នុងស្រុកដែលមានព្រំប្រទល់ជាប់នឹងវៀតណាមខាងត្បូង ដូចជា ស្រុកចន្ទ្រា និងស្រុករមាសហែក។ ទោះបីភូមិតាណវ៍ មិនស្ថិតនៅជាប់ព្រំដែនវៀតណាមក៏ដោយ ក៏ប្រជាជន និងយុវជនក្នុងភូមិនេះត្រូវបានរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរ[2] របស់លោក លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង បានចាប់បង្ខំឱ្យចូលបម្រើកងទ័ពរួចបញ្ជូនទៅវាយជាមួយកងទ័ពបដិវត្តន៍កម្ពុជា[3] ឬកងទ័ពរំដោះខ្មែរក្រហម ដែលគាំទ្រដោយវៀតណាមខាងជើង។

---

[1] រដ្ឋធម្មនុញ្ញសាធារដ្ឋវៀតណាម (The Constitution of the Republic of Vietnam)

[2] រដ្ឋធនុញ្ញាសាធារណរដ្ឋខ្មែរ នាថ្ងៃ១០ ឧសភា ១៩៧២

[3] ទង់បដិវត្ត លេខ២ កុម្ភៈ ឆ្នាំ១៩៧៨ កំណើតនៃកងទ័ពបដិវត្តន៍កម្ពុជា, ទំព័រ៥

យុវជនជាច្រើននៅក្នុងភូមិតាណៅ បានរត់គេចខ្លួនបែកចេញពីគ្រួសារ និងមួយចំនួនបានស្លាប់នៅអំឡុងពេលសង្គ្រាមក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ដែលបណ្តាលឱ្យប៉ះពាល់ដល់ការសិក្សា និងជីវភាពគ្រួសារ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ព និងកម្មាភិបាលខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិតាណៅ ហើយបានជម្លៀសប្រជាជននៅក្នុងភូមិចេញ។ បន្ទាប់មក ខ្មែរក្រហមបានយកផ្ទះរបស់ប្រជាជនដែលស្ថិតនៅជាប់នឹងទន្លេវ៉ៃគោធ្វើជាមន្ទីរ និងកន្លែងសម្លាប់មនុស្ស។

ស្ថានភាពទូទៅ

## ទីតាំងភូមិសាស្ត្រ

ពីសម័យសង្គមរាស្ត្រនិយម រហូតមកដល់សម័យ លន់ នល់ ភូមិតាណៅ ស្ថិតនៅក្រោមរដ្ឋបាលគ្រប់គ្រងរបស់សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង។ ភូមិនេះមានទីតាំងភូមិសាស្ត្រខាងត្បូងជាប់ដៃទន្លេវ៉ៃគោ, ខាងលិចជាប់ភូមិជោរ៍ សង្កាត់ពោធិ៍តាហោ ក្រុងស្វាយរៀង, ខាងកើតជាប់នឹងភូមិឃោសាង ខាងជើងទល់នឹងផ្លូវជាតិលេខមួយចាស់ (រាជរដ្ឋាភិបាលអាណត្តិទី៣ ២០០៣-២០០៨៖ បានសង់កំណាត់ផ្លូវជាតិលេខ១ថ្មីស្ថិតនៅក្នុងសង្កាត់សង្ឃ័រ ក្រុងស្វាយរៀង នៅបែកខាងជើងផ្លូវជាតិលេខ១ចាស់ ដើម្បីវាងផ្លូវជាតិលេខ១ចាស់ប្រវែងប្រមាណជាង៣គីឡូម៉ែត្រ ចំណែកផ្លូវជាតិលេខ១ចាស់ប្តូរទៅជាផ្លូវខេត្តលេខ៣១៤វិញ)។ ក្រោយពេលខ្មែរក្រហមចូលមកគ្រប់គ្រងភូមិតាណៅនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលត្រូវបានផ្លាស់ប្តូរដោយខ្មែរក្រហមបានកាត់ភូមិតាណៅចេញពីសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង មកបញ្ចូលក្នុងឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ តំបន់២៣ ភូមិភាគបូព៌ា។ រហូតមកដល់ឆ្នាំ២០០៩ ទើបមានអនុក្រឹត្យចេញដោយរាជរដ្ឋាភិបាលកម្ពុជា កាត់ឃុំស្វាយតឿ[4] ចេញពីស្រុកកំពង់រោទិ៍ រួចដាក់ឱ្យស្ថិតនៅក្រោមរដ្ឋបាលគ្រប់គ្រងរបស់ក្រុងស្វាយរៀង ខេត្តស្វាយរៀងវិញ។

ពីមុនដោយសារភូមិតាណៅមានទំហំធំ ទើបមានការបែងចែកភូមិសាស្ត្រក្នុងភូមិតាណៅនេះចេញជាពីរផ្នែក ដោយមានប្រឡាយខណ្ឌនៅចំកណ្តាល។ ប្រជាជនដែលរស់នៅខាងត្បូងប្រឡាយទៅទល់នឹងដៃទន្លេវ៉ៃគោប៉ែកខាងត្បូង ប្រជាជននាំគ្នាហៅថា «ភូមិតាណៅខាងត្បូង» ចំណែកប្រជាជនដែលរស់នៅខាងជើងប្រឡាយទល់នឹងផ្លូវជាតិលេខ១ចាស់ និងឃុំសង្ឃ័រ ប្រជាជននាំគ្នាហៅថា «ភូមិតាណៅខាងជើង»។ ប៉ុន្តែការបែងចែកខាងលើនេះ មិនស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលជាផ្លូវការរបស់ឃុំឡើយ។

## មុខរបរ

ប្រជាជននៅក្នុងភូមិតាណៅ (ខាងត្បូង) ភាគច្រើនមានផ្ទះស្ថិតនៅជាប់ប្រឡាយ និងតាមបណ្តោយដៃទន្លេវ៉ៃគោ។ ប្រជាជនភាគច្រើន បានប្រកបរបរធ្វើស្រែប្រាំង-ស្រែវស្សា ចិញ្ចឹមគោ-ក្របី, ជ្រូក មាន់-ទា, ធ្វើស្ករត្នោត, ដាំបន្លែ, រកត្រី សម្រាប់លក់ផ្គត់ផ្គង់ជីវភាពគ្រួសារ និងហូបប្រចាំថ្ងៃ។

---

[4] អនុក្រឹត្យស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្វាយរៀង ទៅជាក្រុងស្វាយរៀង នៃខេត្តស្វាយរៀង ថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩

ចំណែកប្រជាជនដែលរស់នៅភូមិតាណាវ៍ (ខាងជើង) ដែលស្ថិតនៅខាងជើងប្រឡាយ ក៏ប្រកបរបរធ្វើស្រែ ចិញ្ចឹមគោ ក្របី ជ្រូក មាន់ទា ដូចប្រជាជននៅតាណាវ៍ (ខាងត្បូង) ដែរ។

ក្រោយឆ្នាំ១៩៧៩ មានប្រជាជនដែលជាប់សែស្រឡាយចិន-វៀតណាម បានចូលមករស់នៅភូមិតាណាវ៍ជើង និងប្រកបរបរទិញស្រូវ ជ្រូក មាន់ទា ជាក់រ៉ឺម៉កកង់ បើករ៉ឺម៉កម៉ូតូ ជួញស្ករត្នោត ក្រណាត់ អង្ករ បារី ថ្នាំពេទ្យ មាស គ្រឿងបន្លាស់កង់ជាមួយជនជាតិវៀតណាមនៅតាមព្រំដែន។ ប្រជាជនខ្លះទៀតបានប្រកបរបរលក់បន្លែ ត្រី សាច់ និងគ្រឿងទេស នៅផ្សារវាលយន្ត (ផ្សារស្វាយរៀង) ដែលមានចម្ងាយប្រមាណ ៤គីឡូម៉ែត្រ ពីភូមិតាណាវ៍។

**សាលារៀន**

តាំងពីសម័យសង្គមរាស្ត្រនិយម ភូមិនេះមិនមានសាលារៀនទេ ដូច្នេះក្មេងៗត្រូវទៅរៀននៅសាលាវត្ត ឬសាលាបឋម ដែលស្ថិតនៅក្នុងភូមិផ្សេងៗ ដូចជា នៅសាលាបឋមសិក្សាវត្តជម្ពូព្រឹក្សា (វត្តថ្មី) ស្ថិតនៅឃុំសង្ឃ័រ ស្រុកស្វាយទាប, ខេត្តស្វាយរៀង នៅសាលាបឋមសិក្សាវត្តឡ (មានចម្ងាយប្រមាណ៨គីឡូម៉ែត្រពីភូមិតាណាវ៍) ដែលមានទីតាំងស្ថិតនៅក្នុងភូមិស្វាយតឿ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង និងនៅសាលាបឋមសិក្សាដែលស្ថិតនៅក្នុងក្រុងស្វាយរៀង។ បន្ទាប់ពីរៀនចប់បឋមសិក្សា សិស្សក្នុងភូមិតាណាវ៍ ត្រូវទៅរៀនបន្តថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យស្វាយរៀងក្រុងស្ថិតនៅក្រុងស្វាយរៀង។ ក្មេងៗនៅក្នុងភូមិតាណាវ៍ភាគច្រើន មិនបានរៀនចប់ថ្នាក់ទុតិយភូមិទេ ដោយសារជីវភាពខ្វះខាត។ ក្មេងៗទាំងនោះបានឈប់រៀន ហើយត្រលប់មកធ្វើស្រែ ចិញ្ចឹមគោ-ក្របី រកត្រី ជាក់រ៉ឺម៉ក ធ្វើសំណង់ ស៊ីឈ្នួលធ្វើការឱ្យចិន និងមួយចំនួនទៀតបានចំណាកស្រុកទៅធ្វើការនៅកន្លែងផ្សេងៗ។ លើកលែងកូនរបស់ ណៅ ឈ្មោះ សា សុន រស់នៅភូមិតាណាវ៍ (ខាងត្បូង) បានរៀនចប់ផ្នែកវិស្វករអាស្សាណូ និងបានក្លាយជាផលិតករខ្សែភាពយន្តនៅក្រសួងឃោសនាការក្នុងរបប លន់ នល់។ សុន បានត្រលប់មកពីប្រទេសបារាំង នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧២។ សុន មានប្រពន្ធឈ្មោះ អែម ផល មានស្រុកកំណើតនៅករកោង ខេត្តកំពង់ចាម។ សុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែឧសភា នៅឆ្នាំ១៩៧៥ នៅតំបន់២២ រួចបញ្ជូនមកឃុំឃាំងនៅទួលស្លែង និងសម្លាប់ចោល។

**សេវាព្យាបាលជំងឺ**

នៅក្នុងភូមិតាណាវ៍ មិនមានមន្ទីរពេទ្យសម្រាប់ព្យាបាលប្រជាជនតាមបែបវេជ្ជសាស្ត្រទេ គឺមានតែគ្រូខ្មែរបុរាណនៅតាមផ្ទះ និងឆ្មបបុរាណប៉ុណ្ណោះ។ នៅពេលប្រជាជនក្តៅខ្លួន កើតពិស កើតអុតស្វាយ កើតកម រមាស់ និងបូស សមាជិកគ្រួសារត្រូវទៅពឹងពាក់គ្រូខ្មែរឱ្យជួយផ្សំថ្នាំផឹក លាប និងស្តោះផ្លុំ។ ដោយឡែក នៅពេលស្ត្រីសម្រាលកូន ក្រុមគ្រួសារត្រូវទៅពឹងយាយ វ៉ាន់[5] គឺជាឆ្មបបុរាណប្រចាំក្នុងភូមិដើម្បីមកជួយបង្កើត លើកលែងតែមានអាការធ្ងន់ធ្ងរ ទើបបញ្ជូនអ្នកជំងឺទៅព្យាបាលបន្តនៅមន្ទីរពេទ្យខេត្តស្វាយរៀង។ (ទើបតែមកដល់ចុងទសវត្សរ៍ឆ្នាំ១៩៩០ ទើបរាជរដ្ឋាភិបាលបានសាង

[5] វ៉ាន់ គឺជាពេទ្យឆ្មបបុរាណ រស់នៅភូមិតាណាវ៍ (ខាងត្បូង) ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ វ៉ាន់ បានស្លាប់ ហើយកូនចៅរបស់គាត់ក៏មិនបន្តធ្វើជាពេទ្យបុរាណទៀតដែរ។

សង់មណ្ឌលសុខភាពមួយនៅក្នុងភូមិថ្មី ឃុំសង្ឃ័រ ស្រុកស្វាយទាប ដែលនៅជាប់នឹងភូមិតាណរ៍ សម្រាប់ព្យាបាលជំងឺស្រាល ទើបប្រជាជននៅក្នុងភូមិតាណរ៍ មកព្យាបាលជំងឺ និងសម្រាលកូននៅមណ្ឌលសុខភាពនេះ។ ដោយសារមានកង្វះខាតផ្នែកវេជ្ជសាស្ត្រក្នុងការព្យាបាលនៅក្នុងមណ្ឌលសុខភាព ប្រជាជននៅក្នុងភូមិតាណរ៍ដែលមានជីវភាពធូរធារខ្លះ បានធ្វើដំណើរទៅព្យាបាលនៅមន្ទីរពេទ្យក្នុងក្រុងស្វាយរៀង ក្រុងភ្នំពេញ និងនៅប្រទេសវៀតណាម)។

**ការប្រតិបត្តិជំនឿ សាសនា**

តាំងពីសម័យសង្គមរាស្ត្រនិយមរហូតមកដល់សម័យខ្មែរក្រហម ប្រជាជននៅក្នុងភូមិមានជំនឿយ៉ាងមុតមាំទៅលើព្រះពុទ្ធសាសនា។ ជារៀងរាល់ឆ្នាំ ប្រជាជននៅក្នុងភូមិនេះតែងប្រារព្ធធ្វើពិធីបុណ្យទានតាមបែបព្រះពុទ្ធសាសនា និងយកចង្ហាន់ទៅវត្តផ្សេងៗ ដូចជា ទៅវត្តជម្ពូរព្រឹក្សា, វត្តឡ, វត្តកោះ, វត្តសិរីសោភា (ស្ថិតនៅក្នុងឃុំបាសាក់ ស្រុកស្វាយជ្រំ) និងវត្តផ្សេងៗទៀត ព្រោះភូមិនេះមិនមានវត្តទេ។ ក្រៅពីការប្រតិបត្តិព្រះពុទ្ធសាសនា ប្រជាជននៅភូមិតាណរ៍ ក៏មានជំនឿទៅលើការបន់ស្រន់អ្នកតាដែរ។ ប្រជាជននៅក្នុងភូមិ បាននាំគ្នារៃអង្គាសថវិកា ស្រូវអង្ករ ដើម្បីប្រារព្ធធ្វើពិធីបុណ្យឡើងអ្នកតាក្នុងមួយឆ្នាំម្តង។ ពិធីឡើងអ្នកតាត្រូវបានប្រារព្ធធ្វើនៅលើទួលចាស់បុរាណមួយ ស្ថិតនៅកណ្តាលភូមិតាណរ៍ (ខាងត្បូង) ដែលមានដើមឈើទាលធំៗ និងដើមត្នោតដុះព័ទ្ធជុំវិញ។ ប្រជាជននៅក្នុងភូមិមានជំនឿថា ការធ្វើពិធីបុណ្យឡើងអ្នកតានឹងនាំមកនូវសេចក្តីសុខសប្បាយ ចម្រុងចម្រើន មិនមានជំងឺជង្កាត់ក្នុងភូមិ និងមានភ្លៀងគ្រប់គ្រាន់ ហើយការធ្វើស្រែចម្ការក៏បានផលច្រើន។

ដោយឡែក ប្រជាជនដែលជាប់សែស្រឡាយចិន-យួនខ្លះ ដែលរស់នៅក្នុងភូមិតាណរ៍ (ខាងជើង) ខ្លះនៅតែគោរព និងប្រកាន់ខ្ជាប់ខ្លួនប្រពៃណីរបស់ខ្លួន ដូចជា ការប្រារព្ធពិធីបុណ្យសព ពិធីរៀបការ ពិធីចូលឆ្នាំចិន សែនផ្នូរ សែនក្បាលទឹក ជាដើម។ ទោះបីយ៉ាងណា ក៏ប្រជាជនទាំងនេះ បានប្រតិបត្តិតាមប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនាខ្មែរ ដូចជា ធ្វើបុណ្យសង្ឃទាន សូត្រមន្ត ការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំ និងទៅវត្ត ជាដើម។

រដ្ឋប្រហារ

**ដើមដំបូងនៃរបប លន់ នល់**

រហូតមកដល់ថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅខែមីនា ឆ្នាំ១៩៧០[6] ស្ថានភាពនៅក្នុងភូមិតាណរ៍មិនទាន់ជ្រួលច្របល់ខ្លាំងទេ ប៉ុន្តែប្រជាជនភាគច្រើន ក៏មិនពេញចិត្តនឹងរដ្ឋប្រហារនេះដែរ។ ប្រជាជនខ្លះដែលស្មោះស្ម័គ្រ និងគោរពស្រលាញ់សម្តេចព្រះ នរោត្តម សីហនុ បានទៅតវ៉ានៅផ្ទះមេក្រុម, មេភូមិ (មេ៥០ខ្នង) និង មេឃុំ (មេ១០០)។ កែវ សារ៉ុន គឺជាមេក្រុមរស់នៅក្នុងភូមិតាណរ៍ បានរត់គេចចេញពីផ្ទះរបស់ខ្លួនហើយទៅលាក់ខ្លួននៅក្នុងក្រុងស្វាយរៀង ដោយយកទៅជាមួយនូវកាំភ្លើង (ម៉ាតាយើរ) ព្រោះគាត់ខ្លាចប្រជាជនវាយធ្វើបាប។ ស្ថានការណ៍តវ៉ានេះបាន

[6] សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២, ទំព័រ១១៖ នៅខែមីនា ឆ្នាំ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ និងសហការីរបស់ខ្លួនដែលនិយមអាមេរិក បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីព្រះប្រមុខរដ្ឋដោយជោគជ័យ។

ស្ងប់ស្ងាត់ទៅវិញមួយរយៈក្រោយមក។ ចំណែក ប្រជាជននៅក្នុងភូមិតាណេរ៍នៅប្រកបមុខរបររកស៊ី និងធ្វើស្រែ ហើយសិស្សសាលាបានបន្តរៀនសូត្រជម្មតា។

**ចូលបម្រើកងទ័ព**

ក្រោយមក មានយុវជនមួយចំនួននៅក្នុងភូមិទាំងអ្នករៀបការរួច ពិសេសយុវជនដែលនៅលីវ បានស្ម័គ្រចិត្តចូលបម្រើក្នុងទ័ពរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់សេនាប្រមុខ លន់ នល់ រួមមាន សោម ញ៉ូច, សោម សុខ, សោម សាខន, ពេជ្រ លន់, ធី, វ៉ៃ, គិត និង ចិន ដែលមកដល់បច្ចុប្បន្នអ្នកមួយចំនួនបានស្លាប់អស់ហើយ។ ចំពោះអ្នកដែលស្ម័គ្រចិត្តចូលបម្រើកងទ័ព លន់ នល់ នៅពេលនោះ ត្រូវបានបញ្ជូនឱ្យទៅហ្វឹកហាត់ក្បួនទ័ពនៅកំបូលក្នុងក្រុងភ្នំពេញរយៈពេលមួយខែ ទើបបញ្ជូនត្រលប់មកខេត្តស្វាយរៀងវិញ។ កងទ័ព លន់ នល់ ទាំងនោះត្រូវបានអង្គភាពបំពាក់អាវុធឱ្យរួចបញ្ជូនទៅតាមកងរៀងៗខ្លួន។

*សោម សុខ អាយុ៥៦ឆ្នាំ (ក្នុងឆ្នាំ២០១០) រស់នៅភូមិតាណេរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានឈប់រៀនបន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០។ ក្រោយមក សុខ បានចូលបម្រើកងទ័ព លន់ នល់ នៅខេត្តស្វាយរៀង រួមជាមួយប្អូនរបស់គាត់ម្នាក់ទៀតឈ្មោះ សោម ញ៉ូច (បាត់ខ្លួននៅដើមឆ្នាំ១៩៧៥ ពេលរត់គេចពីការបញ្ជូនឱ្យទៅវាយជាមួយកងទ័ពរំដោះខ្មែរក្រហម)។ សុខ ត្រូវបានអង្គភាពបញ្ជូនឱ្យទៅហ្វឹកហាត់ក្បួនយោធារយៈពេលមួយខែនៅកំបូល ក្រុងភ្នំពេញ។ បន្ទាប់ពីហ្វឹកហាត់ចប់ សុខ ត្រូវបានបញ្ចូលក្នុងអង្គភាពវរសេតូចលេខ៤១២ ផ្នែកស៊ើបការណ៍ (ឬហៅម្យ៉ាងទៀតថាក្រុមឆ្មាខ្មៅ) ក្រោមការដឹកនាំរបស់មេបញ្ជាការវរសេនាតូច ស ពៅ។ សុខ ត្រូវបានអង្គភាពបំពាក់កាំភ្លើងខ្លី និងកាំភ្លើងវែង រួចបញ្ជូនឱ្យទៅស៊ើបរកព័ត៌មានខ្មែរក្រហមនៅតាមភូមិផ្សេងៗ ជាមួយសមាជិកក្រុមប្រមាណ៧ នាក់ទៀត។ បើតាមការបញ្ជាក់របស់ សុខ មួយវរសេនាតូច ត្រូវមានក្រុមស៊ើបអង្កេតមួយកង ដែលមានសមាជិកចំនួន ៨នាក់ រួមទាំងប្រធានក្រុមម្នាក់។ សុខ ត្រូវស្លៀកពាក់ខ្មៅ រួចចូលបន្លំខ្លួន និងប្រាស្រ័យទាក់ទងជាមួយប្រជាជននៅតាមភូមិ។ បន្ទាប់មក សុខ យកព័ត៌មានទាំងនេះទៅរាយការណ៍ប្រាប់អង្គភាពវិញ។ ប៉ុន្តែ នៅពេលមានការតាមដានពីកងទ័ពរំដោះខ្មែរក្រហម សុខ ត្រូវលាក់អាវុធ និងសាក់កាដូ ដើម្បីកុំឱ្យកងទ័ពរំដោះសង្ស័យ។ មានហេតុការណ៍វាយប្រយុទ្ធគ្នាជាមួយកងទ័ពរំដោះខ្មែរក្រហម ជាមួយកងទ័ព លន់ នល់ នៅក្នុងស្រុកស្វាយជ្រុំ ដែលស្ថិតនៅចម្ងាយប្រមាណ ៧គីឡូម៉ែត្រពីភូមិតាណេរ៍ ពេលនោះ សុខ បានបោះសាក់កាដូចោល និងលាក់អាវុធទាំងអស់។ សុខ ត្រូវបានប្រធានកងឈ្មោះ សយ ផ្តាំផ្ញើឱ្យយកអង្ករទៅតាមខ្លួន តែដោយសារធ្ងន់ពេកមិនអាចស្ពាយតាមខ្លួនបាន សុខ យកតែសៀវភៅគម្ពីរធម៌ និងព្រះត្រៃបិដកប៉ុណ្ណោះ ព្រោះខ្លាចកងទ័ពរំដោះខ្មែរក្រហមដុតបំផ្លាញ។ សុខ ត្រូវមេកងស្តីបន្ទោស និងខឹងយ៉ាងខ្លាំងនៅពេលត្រលប់មកដល់អង្គភាពវិញ។ បើតាម សុខ មេក្រុម និងបញ្ជាការនៅសម័យនោះកាច និងមានវិន័យតឹងតែងណាស់ ហើយសូម្បីពុកមាត់របស់មេបញ្ជាការទាំងនោះ ក៏អង្គភាពគិតជាប្រាក់ខែឱ្យដែរ។*

**ការបង្កើតទីតាំងយោធា**

នៅដំណាក់កាលដំបូងៗនៃរដ្ឋប្រហារ នៅឆ្នាំ១៩៧០ នៅក្នុងខេត្តស្វាយរៀងមិនមានការវាយប្រយុទ្ធគ្នាខ្លាំងក្លាទេរវាងកងទ័ព លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ កងទ័ពរបស់ លន់ នល់ រួមជាមួយរថពាសដែកប្រមាណបីគ្រឿងត្រូវបានបញ្ជូនទៅល្បាត និងប្រចាំការនៅព្រំដែនវៀតណាម ដូចជា នៅបាវិតផ្លូវជាតិលេខ១។

ពេលនោះ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ក៏បានរៀបចំបង្កើតទីតាំងសំខាន់ៗដែលត្រូវយាមការពារនៅតាមទីប្រជុំជនក្នុងខេត្តស្វាយរៀង មានដូចជា បន្ទាយទាហាន, ឃ្លាំងផ្ទុកសម្ភារ, ប៉ុស្តិ៍ត្រួតពិនិត្យនៅព្រំដែន និងច្រកព្រំដែន។[7] ទីតាំងទាំងនោះ ស្ថិតនៅក្នុងតំបន់ដូចខាងក្រោម៖

- បន្ទាយទាហាន នៅកំពង់ត្រាច
- បន្ទាយទាហាន នៅឃុំចក
- បន្ទាយទាហាន នៅឃុំប្រសូត្រ,
- បន្ទាយទាហាន នៅភូមិនាវា
- ឃ្លាំងផ្ទុកសម្ភារ នៅក្រុងស្វាយរៀង
- ឃ្លាំងផ្ទុកសម្ភារ នៅឃុំសំបួរ
- ទីតាំងសំខាន់ដែលត្រូវការពារ បាធូ
- ទីតាំងសំខាន់ដែលត្រូវការពារ បូ មារ
- ទីតាំងសំខាន់ដែលត្រូវការពារ ចន្ទ្រា
- ប៉ុស្តិ៍ត្រួតពិនិត្យ ជីភូ
- ប៉ុស្តិ៍ការពារព្រំដែន ពាមមេត្រី
- ទីតាំងសំខាន់ដែលត្រូវការពារ នៅឃុំចម្លង
- ទីតាំងសំខាន់ដែលត្រូវការពារ នៅភូមិអំពិល
- ទីតាំងសំខាន់ដែលត្រូវការពារ នៅភូមិល្បួង
- ទីតាំងសំខាន់ដែលត្រូវការពារ នៅភូមិតាម៉េញ
- ទីតាំងសំខាន់ដែលត្រូវការពារ នៅភូមិព្រៃក្រូច
- ទីតាំងខ្សែក្រវ៉ាត់ក្រុងដែលត្រូវការពារ នៅក្រុងស្វាយរៀង។

*ចំណែកកងទ័ពត្រូវបានរៀបចំជា ៖*

- ផ្នែក (Section) ដោយក្នុងមួយផ្នែកមានកងទ័ព ៣០នាក់
- អនុសេនាធំ (Company) ដោយក្នុងមួយអនុសេនាធំមានកងទ័ព១០០ ទៅ១២០នាក់
- វរសេនាតូច (Regiment) ដោយក្នុងមួយវរសេនាតូចមានកងទ័ព ៣០០ ទៅ ៤០០នាក់

[7] ឯកសារស៊ីអាយអេ ៖ របាយការណ៍វិភាគភូមិសាស្ត្រតាមផ្កាយរណប ៖ សកម្មភាពយោធា និងការបះបោរ នៅខេត្តស្វាយរៀង ប្រទេសកម្ពុជា (Central Intelligence Agency: Imagery Analysis Report-Military and Insurgent Activity Svay Rieng Province, Cambodia).

- វរសេនាធំ (Battalion) ដោយក្នុងមួយវរសេនាធំមានកងទ័ព ៩០០ ទៅ ១០០០នាក់

ក្រោយមក ដោយសារមានកងទ័ពរត់ចោលជួរ កងវរសេនាធំខ្លះនៅសល់ទ័ពតែជាង ៥០០ នាក់ប៉ុណ្ណោះ។

*ក្នុងចំណោមកងទ័ពទាំងអស់ក្នុងខេត្តស្វាយរៀង ត្រូវបានបែងចែកចេញជាបីកងវរសេនាតូច ៖*

១) វរសេនាតូចលេខ៤១២ ដឹកនាំដោយ ស ពៅ

២) វរសេនាតូចលេខលេខ៣៩ ដឹកនាំដោយ កែវ ថុន (នៅពេលកងទ័ពរំដោះខ្មែរក្រហមរំដោះបានខេត្តស្វាយរៀង នៅឆ្នាំ១៩៧៥ កែវ ថុន បានកុហកខ្មែរក្រហមថា រកស៊ីលក់ដូរ រួចក៏ធ្វើដំណើរទៅរស់នៅខេត្តក្រចេះ) និង

៣) វរសេនាតូចលេខ ២៤ ដឹកនាំដោយ ប៊ិន (ទើបបង្កើតបានមួយរយៈពេលខ្លីក៏ដកទៅវិញ)

**ការជ្រៀតចូលរបស់កងទ័ពវៀតកុង**

នៅអំឡុងពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅឆ្នាំ១៩៧០ មានកងទ័ពវៀតកុង ដែលមានឈ្មោះជាផ្លូវការ «រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង[8]» រាប់ពាន់នាក់ បានធ្វើដំណើរឆ្លងកាត់ខេត្តតាយនិញ ក្នុងទឹកដីវៀតណាមខាងត្បូង រួចឆ្លងកាត់ដៃទន្លេវ៉ៃគោ[9] ដែលនៅជាប់នឹងភូមិតាណរវឹប៉កខាងត្បូង សំដៅទៅតំបន់ឡុងខូត[10] (Long Khốt) ក្នុងទឹកដីប្រទេសវៀតណាមខាងត្បូង។ កងទ័ពវៀតកុង បានធ្វើដំណើរគេចពីការតាមឃ្លាំមើលរបស់យន្តហោះអាមេរិក។ នៅពេលយន្តហោះកងទ័ពអាមេរិកហោះមកឆ្វែលម្តងៗ កងទ័ពវៀតកុង បានអង្គុយជាជួរតម្រៀបនៅតាមវាលដើម្បីបន្លំជាភ្លឺស្រែ។ កងទ័ពវៀតកុងទាំងនេះ បានទៅសម្រាកនៅក្រោមដើមពោធិ៍តាស្លែង នៅជាប់នឹងដៃទន្លេវ៉ៃគោ ដើម្បីរង់ចាំឆ្លងចូលទៅវាយជាមួយកងទ័ពជីវគី នៃសាធារណរដ្ឋវៀតណាម ឬកងទ័ពវៀតណាមខាងត្បូង។ កងទ័ពវៀតកុង មិនបានប៉ះទង្គិចជាមួយកងទ័ពរបស់ លន់ នល់ ទេ។ ប៉ុន្តែក្រោយៗមក ក៏មានហេតុការណ៍វាយប្រយុទ្ធគ្នាបានកើតឡើង គឺកងទ័ពវៀតកុងបានដើរច្រឡំចូលខ្សែត្រៀមរបស់កងទ័ព លន់ នល់ ដែលបោះបន្ទាយទាហាននៅប្រសូត្រ។ កងទ័ពវៀតកុងចំនួនប្រមាណ ៣០ នាក់ ត្រូវបានកងទ័ព លន់ នល់ បាញ់សម្លាប់ រួចបញ្ជូនសាកសពមកដុត នៅក្រុងស្វាយរៀង។

**ការវាយប្រយុទ្ធ និងការរត់ចោលជួរ**

ដោយសារខេត្តស្វាយរៀង មានព្រំប្រទល់ជាប់វៀតណាមភាគខាងត្បូង ដូច្នេះហើយទើបកងទ័ពវៀតកុងបានឆ្លងកាត់ភូមិសាស្ត្រខេត្តនេះជាញឹកញាប់។ ចំណែក កងទ័ពរំដោះខ្មែរក្រហម ដែលគាំ

---

[8] https://km.wikipedia.org/wiki/%E1%9E%9C%E1%9F%80%E1%9E%8F%E1%9E%80%E1%9E%BB%E1%9E%84

[9] https://www.information.gov.kh/articles/127351

[10] ឡុងខូត ស្ថិតនៅក្នុងភូមិដុងជឿក ឃុំថៃប៊ិញដុង ស្រុកវិញហ៊ឹង ខេត្តឡុងអាន ប្រទេសវៀតណាម។ ប្រជាជននៅក្នុងខេត្តស្វាយរៀងហៅ ឡុងខូត ថា ត្រឡោងខូស ដែលមានព្រំប្រទល់ជាប់ជាមួយភូមិឫស្សីលៀប ឃុំសំយ៉ោង ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

ទ្រដោយកងទ័ពវៀតកុង ក៏បានធ្វើសកម្មភាព និងវាយប្រហារកាន់តែខ្លាំងក្លាប្រឆាំងនឹងកងទ័ព លន់ នល់ នៅសមរភូមិសំខាន់ៗ ដូចជា នៅសមរភូមិប្រសូត្រ[11], ចក[12] និងនៅអូរសំដី[13] ។ មានការប្រយុទ្ធគ្នាជាច្រើនលើកនៅសមរភូមិអូរសំដី ហើយរាល់ការប្រយុទ្ធគ្នាម្តងៗបានបណ្តាលឱ្យកងទ័ព លន់ នល់ ប្រមាណ ១៥ ទៅ៣០នាក់បានស្លាប់។ សពយុទ្ធជនទាំងនោះ ត្រូវបានបញ្ជូនមកតម្កល់នៅវត្តព្រៃធ្លាក់ ស្ថិតនៅខាងជើងក្រុងស្វាយរៀង ដើម្បីកត់អត្តលេខទុកឱ្យឪពុកម្តាយ និងបងប្អូនបើកប្រាក់ខែ។ បន្ទាប់មកទើបកងទ័ព លន់ នល់ ដែលប្រចាំការនៅទីនោះ បានបូជាសាកសពដើម្បីរើសអដ្ឋិធាតុរក្សាទុកឱ្យក្រុមគ្រួសារ។

ចាប់ពីឆ្នាំ១៩៧៣ ការវាយប្រយុទ្ធគ្នាកាន់តែខ្លាំងក្លាឡើងរវាងកងទ័ព លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ ដូច្នេះ រដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់ លន់ នល់ ក៏ត្រូវការយុវជននៅក្នុងខេត្តស្វាយរៀង កាន់តែច្រើនឡើងឱ្យចូលធ្វើកងទ័ព។ មេភូមិតាណៃ ឈ្មោះ ផាន់ ក៏ចាប់ផ្តើមដើរស្រង់ឈ្មោះយុវជនឱ្យចូលទាហាន និងយុវជនមួយចំនួនទៀតត្រូវបានប៉េអឹមចុះមកចាប់បង្ខំឱ្យចូលធ្វើកងទ័ពតែម្តង។ ក្នុងចំណោមយុវជនដែលចាប់បង្ខំឱ្យចូលកងទ័ព លន់ នល់ ទាំងនោះ ក៏មាន កែវ សារ៉ន និង អុន រស់នៅក្នុងភូមិតាណៃដែរ។

*កែវ សារ៉ន អាយុ៥៦ឆ្នាំ (ក្នុងឆ្នាំ២០១០) រស់នៅភូមិតាណៃ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានឱ្យដឹងថា អុន បានរត់ចូលពួនក្នុងទូដាក់ខោអាវនៅលើផ្ទះ ដើម្បីគេចពីការតាមចាប់ឱ្យចូលធ្វើកងទ័ព ប៉ុន្តែ អុន គេចមិនរួចឡើយ។ នៅឆ្នាំ១៩៧៤ រ៉ន បានឈប់រៀន តែគាត់នៅកាន់កាតសិស្សដដែល។ រយៈពេលកន្លះឆ្នាំក្រោយមក មេភូមិឈ្មោះ ផាន បានរាយការណ៍ទៅខាងអង្គភាពកងទ័ពដើម្បីបញ្ជូន រ៉ន ឱ្យចូលបម្រើកងទ័ព ដោយសារកាតសិស្សរបស់ រ៉ន ផុតកំណត់។ រ៉ន និង អុន ត្រូវបានបញ្ជូនតាមយន្តហោះឱ្យទៅហ្វឹកហាត់ក្បួនយោធានៅកំបូល ចម្ងាយប្រមាណជាង ១០គីឡូម៉ែត្រខាងលិចក្រុងភ្នំពេញ។ រ៉ន ហ្វឹកហាត់នៅកំបូលរយៈពេលមួយខែ ក៏ត្រលប់មកខេត្តស្វាយរៀងវិញ។ រ៉ន បានមកនៅវរសេនាតូច៣៩ ផ្នែកកុម្មង់ដូ។ បន្ទាប់មក ខាងអង្គភាពក៏បានបំពាក់អាវុធឱ្យ រ៉ន រួចហើយក៏បញ្ជូន រ៉ន ឡើងទៅវាយជាមួយកងទ័ពរំដោះខ្មែរក្រហមនៅសមរភូមិអូរសំដី ដែលមានចម្ងាយប្រមាណជាង ១០គីឡូម៉ែត្រ បែកខាងជើងក្រុងស្វាយរៀង។ ក្រោយមក វរសេនាតូចរបស់ រ៉ន ទទួលបញ្ជាឱ្យបញ្ជូនទ័ពឡើងទៅវាយជាមួយកងទ័ពរំដោះខ្មែរក្រហមនៅកោះធ្លូញ (ខាងកើតក្រុងភ្នំពេញ) ស្ថិតនៅក្នុងស្រុកល្វាឯម ខេត្តកណ្តាល។ ពេលសមាជិកកងវរសេនាតូចលេខ៣៩ របស់ រ៉ន ឡើងជិះលើរថយន្តបានពាក់កណ្តាល រ៉ន ក៏ស្នើសុំមេកងឈ្មោះ ធី ដោយកុហកថា ទៅបត់ជើងធំ។ ធី បាន*

[11] ភូមិប្រសូត្រ ស្ថិតនៅឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមប្តូរទៅជាស្រុកប្រសូត្រ តំបន់២៣ ភូមិភាគបូព៌ា។

[12] ភូមិចក ស្ថិតនៅឃុំកំពង់ចក ស្រុករំដួល ខេត្តស្វាយរៀង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមប្តូរទៅជាស្រុកសំរោង តំបន់២៣ ភូមិភាគបូព៌ា។

[13] ភូមិអូរសំដី ស្ថិតនៅឃុំពោធិ៍រាជ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមប្តូរទៅជាស្រុកមានជ័យថ្មី តំបន់២៣ ភូមិភាគបូព៌ា។

*អនុញ្ញាតជាមួយនឹងបទបញ្ជាថា «ត្រូវប្រញាប់ត្រលប់មកវិញឱ្យឆាប់»។ ឆ្លៀតឱកាសនោះ រ៉េន បានគេចត្រលប់មកផ្ទះវិញ។*

ពីមួយថ្ងៃទៅមួយថ្ងៃ ស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងក្រុងស្វាយរៀង និងប្រជាជននៅភូមិតាណវ៍ ជាពិសេសយុវជនដែលឈប់រៀនកាន់តែលំបាកទៅៗ។ រៀងរាល់ពេលដែលមានប៉េអឹម និងមន្ត្រីភូមិចុះមកម្តងៗ យុវជនទាំងនេះតែងរត់គេច និងលាក់ខ្លួនទាំងភ័យស្លន់ស្លោ។

*សោម សុខ ត្រូវបានផ្តល់ដំណឹងពីបងប្អូនជីដូនមួយដែលរកស៊ីជួញដូរ មកថា ខាងអង្គភាពទ័ព និង ប៉េអឹម បានមកតាមរកឱ្យត្រលប់ទៅអង្គភាពវិញ ព្រោះនៅពេលមានការវាយប្រយុទ្ធគ្នាខ្លាំង នៅដើមឆ្នាំ១៩៧៥ អង្គភាពបានបញ្ជូន សុខ តាមយន្តហោះឱ្យឡើងទៅវាយជាមួយកងទ័ពរំដោះខ្មែរក្រហម នៅម្តុំស្រុកបាភ្នំ ខេត្តព្រៃវែង ប៉ុន្តែ សុខ បានលួចរត់ត្រលប់មកផ្ទះវិញ។ នៅពេលទទួលបានដំណឹងនេះ សុខ បានរត់គេចចេញពីផ្ទះទៅលាក់ខ្លួននៅកន្លែងផ្ទុកសម្បកកង់ឡានចាស់ៗនៅផ្ទះបងរហូតដល់ប៉េអឹមចាកចេញទៅបាត់ ទើបគាត់ហ៊ានត្រលប់មកផ្ទះវិញ។*

ចំណែកការធ្វើដំណើរ និងទំនាក់ទំនងរបស់ប្រជាជននៅក្នុងភូមិតារណ៍ទៅកាន់បងប្អូននៅភូមិផ្សេងក៏មានការលំបាកដែរ ព្រោះកងទ័ពរំដោះខ្មែរក្រហមបានវាយចូលមកកៀកភូមិ និងទីប្រជុំជនសំខាន់ៗនៅក្នុងខេត្តស្វាយរៀង។ ចំណែកទីតាំងបន្ទាយទាហាន និងប៉ុស្តិ៍ត្រួតពិនិត្យសំខាន់ៗរបស់ទាហាន លន់ នល់ ក៏បានរំកិលពីព្រំដែនមកបោះទីតាំងនៅកៀកនឹងក្រុងស្វាយរៀងដែរ។ បន្ទាយទាហានរបស់ លន់ នល់ មួយបានមកបោះទីតាំងនៅវត្តទ្បួ ក្នុងភូមិស្វាយតឿ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីភូមិតាណវ៍ (ខាងត្បូង)។

រហូតមកដល់ដើមឆ្នាំ១៩៧៥ ទីតាំងរដ្ឋបាលរបស់ខេត្តស្វាយរៀង ដែលគ្រប់គ្រងដោយឧត្តមសេនីយ៍ ណុប ប៉ាម៉ុន បានរួមតូចទៅៗដោយនៅសល់ដីត្រឹមតែជាង ១០គីឡូម៉ែត្រប៉ុណ្ណោះជុំវិញក្រុងស្វាយរៀង ដោយខាងកើតទល់នឹងឃុំប្រសូត្រ, ខាងជើងទល់នឹងឃុំកំពង់ចក, ខាងលិចទល់នឹងស្ពានកន្ទុយវ៉ៃ[14] និងខាងត្បូងទល់វត្តកោះជុំ។[15] ដូច្នេះ រាល់ការធ្វើដំណើរ ការផ្គត់ផ្គង់ស្បៀងអាហារ អង្ករ ទៅដល់កងទ័ព និងប្រជាជនដែលរស់នៅក្នុងក្រុងស្វាយរៀង ត្រូវដឹកតាមយន្តហោះឯកជន ម៉ាកដាកូតា ដែលអាចផ្ទុកអង្ករទម្ងន់ ៥-៦តោនក្នុងមួយជើង ចុះចតនៅវាលយន្តហោះស្ថិតនៅម្តុំស្ពានកន្ទុយវ៉ៃជាប់នឹងខ្សែត្រៀមប្រយុទ្ធ។ ចំណែកការដឹកជញ្ជូនសម្ភារយោធា និងកងទ័ព គឺត្រូវដឹកជញ្ជូនតាមយន្តហោះយោធា ដែលចុះចតនៅជិតវត្តកោះជុំ ចម្ងាយប្រមាណជាងបីគីឡូម៉ែត្រប៉ែកខាងត្បូងក្រុងស្វាយរៀង។

ការមកដល់នៃរបបខ្មែរក្រហម

---

[14] ស្ពានកន្ទុយវ៉ៃ ស្ថិតនៅក្នុងឃុំចេក ក្រុងស្វាយជ្រុំ ខេត្តស្វាយរៀង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមប្តូរទៅជាស្រុកមានជ័យថ្មី តំបន់២៣ ភូមិភាគបូព៌ា។

[15] វត្តកោះជុំ ស្ថិតនៅភូមិតាពងបាល់ ឃុំគយត្របែក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមប្តូរទៅជាស្រុកមានជ័យថ្មី តំបន់២៣ ភូមិភាគបូព៌ា។

## ការជម្លៀសលើកទី១

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ត្រូវនឹងថ្ងៃចូលឆ្នាំប្រពៃណីខ្មែរ កងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ក្រុងស្វាយរៀង ដោយមិនមានការវាយប្រយុទ្ធគ្នាខ្លាំងក្លាជាមួយកងទ័ព លន់ នល់ ទេ។ នៅពេលនោះ ទាហាន មន្ត្រីរាជការ ពេទ្យ គ្រូបង្រៀន ពាណិជ្ជករ និងប្រជាជនដែលរស់នៅក្នុងក្រុងស្វាយរៀង ត្រូវកងទ័ពរំដោះខ្មែរក្រហមជម្លៀសទៅទិសខាងលិចតាមបណ្ដោយផ្លូវជាតិលេខ១ និងប្រមូលផ្ដុំគ្នានៅស្រុកស្វាយជ្រុំ ដើម្បីស្រង់ប្រវត្តិរូបដែលមានសមមិត្ត ធុច (អតីតគ្រូបង្រៀន) គ្រប់គ្រងនៅទីនោះ។ ដោយឡែកប្រជាជននៅក្នុងភូមិតាណរ៍ ប្រមាណជាង ២០០គ្រួសារ ដែលរស់នៅប៉ែកខាងកើតក្រុងស្វាយរៀង ត្រូវបានខ្មែរក្រហមជម្លៀសឱ្យទៅនៅគោកព្រីង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ ក្រោយមក ទើបជម្លៀសទៅស្រុកកៀនស្វាយ ខេត្តកណ្ដាល។

ដោយឡែកប្រជាជនរស់នៅក្នុងភូមិតាណរ៍ដែលខ្មែរក្រហមជម្លៀសឱ្យទៅរស់នៅ និងធ្វើការតាមតំបន់រំដោះផ្សេងៗតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មួយចំនួនតូច ត្រូវបានខ្មែរក្រហមឱ្យចូលមករស់នៅក្នុងភូមិចាស់របស់ខ្លួនវិញនៅរដូវធ្វើស្រែ ហើយមួយចំនួនទៀត គឺបានបែងចែកឱ្យទៅរស់នៅភូមិទាហានលើ និងភូមិទាហានក្រោម ក្នុងឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ បន្ទាប់មកខ្មែរក្រហមបានបញ្ជូនឈ្មោះ ធន ដែលមានមាឌតូច និងសម្បុរស គឺជាប្រជាជនមូលដ្ឋានរស់នៅឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ឱ្យមកគ្រប់គ្រងភូមិតាណរ៍, ឈ្មោះ ម៉ី គឺជាប្រជាជនមូលដ្ឋានរស់នៅភូមិសាមគ្គីឱ្យឡើងទៅជាគណៈឃុំស្វាយតឿ,ឈ្មោះ ជា ធ្វើជាអនុប្រធានឃុំស្វាយតឿ និងឈ្មោះ មី សារូ ប្រធានសហករណ៍ភូមិតាណរ៍។

*សោម សន*[16] *ភេទស្រី អាយុ ៦២ឆ្នាំ (នៅក្នុងឆ្នាំ២០០៥) កើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃគាត់រស់នៅភូមិដដែលមានប្រសាសន៍ថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសគាត់ឱ្យទៅរស់នៅភូមិទាហានក្រោម។ នៅទីនោះ ខ្មែរក្រហមប្រើគាត់លើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយ ដកស្ទូង គ្មានពេលឈប់សម្រាកឡើយ។ ចំណែក របបអាហារ គាត់ទទួលបានបាយមួយចាន ប៉ុន្តែគាត់ហូបមិនដែលបានឆ្អែតឡើយ។ ក្រោយមកខ្មែរក្រហមបានបញ្ជូនគាត់ឱ្យទៅជីកប្រឡាយ និងស្រះទឹកធំៗនៅស្រុករមាសហែក។*[17] *ថ្ងៃខ្លះខ្ញុំធ្វើការរហូតដល់ម៉ោង១០យប់ទើបបានឈប់សម្រាក ហើយពេលថ្ងៃខ្ញុំត្រូវទៅច្រូតស្រូវនៅព្រំដែនវៀតណាម។ ពេលខ្លះមានគ្រាប់ផ្លោងដាក់កងច្រូតស្រូវរបស់គាត់ទៀតផង។ បន្ទាប់ពីចប់រដូវច្រូត ខ្មែរក្រហម បានបញ្ជូនគាត់ឱ្យត្រលប់មកដកស្ទូងនៅភូមិទាហានក្រោមវិញ។ នៅចុងឆ្នាំ១៩៧៦ ខ្មែរក្រហមជម្លៀសគាត់ឱ្យទៅរស់នៅស្រុកកៀនស្វាយ ខេត្តកណ្ដាល។ នៅទីនោះ គាត់ធ្វើពលកម្មធ្ងន់ធ្ងរជាងនៅភូមិទាហានក្រោម ព្រោះគាត់ត្រូវ*

[16] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារទ3166, បទសម្ភាសន៍ កែវ ដួង ជាមួយ សោម សន ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៥។

[17] ស្រុករមាសហែក នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ខ្មែរក្រហមប្ដូរទៅជាស្រុកក្រសាំង តំបន់២៣ ភូមិភាគបូព៌ា។

*មុជទឹកជីកដីមកចាក់ធ្វើប្រឡាយ។ គាត់ត្រូវក្រោកពីម៉ោង ៣ទៀបភ្លឺ ទៅលើកប្រព័ន្ធប្រឡាយរហូតដល់ម៉ោង១២ ឬម៉ោង ១រសៀលទើបបានឈប់សម្រាក។ គាត់រស់នៅស្រុកកៀនស្វាយបែកពីបងប្អូន និងឪពុកម្តាយរហូតដល់កងទ័ពវៀតណាមវាយចូលមក នៅដើមឆ្នាំ១៩៧៩ ទើបត្រលប់មកស្រុកកំណើតវិញ។*

*ពេជ្រ សុន[18] ភេទប្រុស អាយុ ៤៨ឆ្នាំ (នៅក្នុងឆ្នាំ២០០៥) កើតនៅភូមិតាណោវ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃគាត់រស់នៅភូមិដដែលមានប្រសាសន៍ថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងគាត់ឱ្យទៅធ្វើស្រែនៅភូមិទាហានក្រោម ក្នុងឃុំស្វាយតឿ បន្ទាប់មកដកគាត់ឱ្យមកជីកប្រឡាយនៅភូមិតាណោវ៍រយៈពេល ៣ខែ។ ដំបូងការងាររបស់គាត់នៅភូមិតាណោវ៍មិនសូវលំបាកទេ។ ក្រោយមកទើប ខ្មែរក្រហមបញ្ជូនគាត់ឱ្យទៅជីកប្រឡាយនៅក្នុងស្រុកកំពង់រោទិ៍ ជាប់ព្រំដែនវៀតណាម។ ប្រឡាយនោះមានប្រវែង ១គីឡូម៉ែត្រ ជម្រៅ ៣ម៉ែត្រ និងមាត់លើ ១៥ម៉ែត្រ ដូច្នេះគាត់ត្រូវធ្វើការងារគ្មានពេលសម្រាកឡើយ។ ចំណែករបបអាហារ គាត់ហូបមិនគ្រប់គ្រាន់ទេ គឺខ្មែរក្រហមចែកអង្ករកន្លះកំប៉ុងសម្រាប់មនុស្សពីរនាក់ក្នុងមួយពេល។ ប្រសិនបើសមាជិកកងណាម្នាក់មានជំងឺ ប្រធានកងអនុញ្ញាតឱ្យទៅព្យាបាលនៅមន្ទីរពេទ្យតំបន់ ប៉ុន្តែគ្មានថ្នាំល្អឡើយ។ អ្នកដែលឈឺស្រាល គឺនៅធ្វើការដដែល។ ដោយឡែកអ្នកដែលធ្វើពុតជាឈឺ ហើយប្រធានកងដឹងនឹងយកទៅរៀនសូត្រ ឬសម្លាប់ចោលមិនខាន។ សុន ធ្លាប់កងឈ្លបឈ្មោះ ចាន់ រស់នៅបន្ទាយក្រាំង ឃុំបន្ទាយក្រាំង ហៅទៅណែនាំ។ នៅខែវស្សាប្រធានកងចាត់តាំង សុន ឱ្យមកធ្វើស្រែនៅភូមិតាណោវវិញ។ នៅឆ្នាំ ១៩៧៧ ខ្មែរក្រហមបានជម្លៀសគាត់ឱ្យទៅស្រុកកៀនស្វាយ ខេត្តកណ្តាលវិញ។ នៅទីនោះ គាត់ធ្វើស្រែវស្សា និងលើកទំនប់ រហូតដល់ទឹកជំនន់ខ្លាំងទើបទប់។ គាត់រស់នៅកៀនស្វាយ រហូតដល់ប្រទេសកម្ពុជាត្រូវបានរំដោះនៅឆ្នាំ១៩៧៩។*

**ការបែងចែករចនាសម្ព័ន្ធគ្រប់គ្រងថ្មី**

ខ្មែរក្រហមបានរៀបចំ និងបែងចែករចនាសម្ព័ន្ធគ្រប់គ្រងថ្មី ដោយកាត់ភូមិតាណោវ៍ ចេញពីសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង បញ្ចូលមកនៅក្នុងឃុំស្វាយតឿ ស្រុកកំពង់រោទិ៍វិញ។ ពេលនោះមន្ទីរឃុំស្វាយតឿ បោះទីតាំងនៅវត្តឡ ស្ថិតនៅក្នុងភូមិស្វាយតឿ និងមានចម្ងាយប្រមាណជិត១០ គីឡូម៉ែត្រពីក្រុងស្វាយរៀង (ក្រោយរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ មន្ទីរឃុំស្វាយតឿ ត្រូវបានផ្លាស់មកនៅភូមិតាណោវវិញ)។ ក្រៅពីភូមិតាណោវ៍ ខ្មែរក្រហមក៏បានបញ្ចូលភូមិមួយចំនួនទៀតចូលក្នុងឃុំស្វាយតឿ រួមមាន ភូមិស្វាយតឿ, ភូមិតាដោវ៍, ភូមិឃោសាង, ភូមិសាមគ្គី, ភូមិទាហានលើ និងភូមិទាហានក្រោម។

ប្រជាជននៅភូមិតាណោវ៍ នៅពេលនោះត្រូវបានបែងចែកចេញទៅជាកង ៖

[18] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03205 បទសម្ភាសន៍ លាក់ ជ័យរិទ្ធី ជាមួយ ពេជ្រ សុន នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

- «កងកុមារ» រួមមាន ក្មេងៗដែលមានអាយុតិចៗ។ កងនេះធ្វើការងារស្រាលៗ ដូចជា រើសអាចម៍គោ និងកាប់ទន្ទ្រានខេត្ត។

-«កងចល័ត» រួមមាន យុវជន យុវនារី ដែលនៅលីវ។ កងនេះ ធ្វើស្រែ ស្ទូងស្រូវ និងជីកប្រឡាយ។

- «កងតាៗ» ធ្វើការងារ ត្បួរ និងវាស់វែងដីឱ្យកងចល័តជីក។ ចំណែក កងយាយៗ ក្រងកន្ទេល កញ្ច្រែង ល្អី និងមើលថែទាំក្មេងៗ។

*ប្រាក់ ថាវី[19] ភេទស្រី អាយុ ៣៩ឆ្នាំ (នៅក្នុងឆ្នាំ២០០៥) កើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃគាត់រស់នៅភូមិដដែលបានមានប្រសាសន៍ថា នៅឆ្នាំ ១៩៧៥ គាត់នៅក្នុងកងកុមារ។ ខ្មែរក្រហមបានចាត់តាំងគាត់ឱ្យឃ្វាលក្របី ដេញចាប និងចាប់កណ្ដុរ ដែលកាត់ស្រូវឱ្យបានចំនួន ១០ក្បាលក្នុងមួយថ្ងៃ។ គាត់រស់នៅជុំជាមួយឪពុកម្ដាយ ប៉ុន្តែពេលហូបអាហារគាត់ត្រូវទៅហូបនៅមណ្ឌលកុមារ ដែលមានបាយ និងបបរ។ គាត់ត្រូវបានប្រធានកងហៅទៅកសាងម្ដង ដោយប្រធានឱ្យគាត់ឡើងសារភាពថា «សូមមិត្តនៅក្នុងកងកុំយកគម្រាប់តាមគាត់»។*

*ពេជ្រ សុផាត[20] ភេទស្រី អាយុ៤២ឆ្នាំ (នៅក្នុងឆ្នាំ២០០៥) កើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃគាត់រស់នៅភូមិដដែលបានមានប្រសាសន៍ថា កាលពីរបបខ្មែរក្រហម គាត់នៅកុមារភាព ដូច្នេះខ្មែរក្រហមប្រើគាត់ឱ្យឃ្វាលគោ ក្របី និងដើររើសក្តួរស្រូវតាមវាលស្រែ។ ចំណែកម្ដាយរបស់គាត់ ខ្មែរក្រហមចាត់តាំងឱ្យមើលថែទាំក្មេងៗ ហើយឪពុករបស់គាត់យាមចម្ការដំឡូង។ នៅពេលចប់ម៉ោងការងារ គាត់ទទួលបានរបបបបរមួយវែកក្នុងមួយពេល ហើយបន្ទាប់ពីហូបរួច គឺគាត់ធ្វើការងារបន្តទៀត។ នៅពេលយប់ប្រធានកងកុមារ បានកោះហៅសមាជិកក្រុមមកប្រជុំ និងលើកឡើងពីគុណសម្បត្តិ និងគុណវិបត្តិរបស់សមាជិកក្រុមម្នាក់ៗដើម្បីជួយកែលម្អគ្នា។*

*ឡឹក ឆោម[21] ភេទប្រុស អាយុ៥០ឆ្នាំ (ក្នុងឆ្នាំ២០០៥) មានស្រុកកំណើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃរស់នៅភូមិដដែលមានប្រសាសន៍ថា នៅឆ្នាំ ១៩៧៥ ខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យចូលកងចល័ត និងទៅជីកប្រឡាយនៅវត្តឧត្តុង្គ[22] (វត្តពេជ្រមន្ត្រី)។ នៅទីនោះ កងឈ្លបបានយកខ្ញុំទៅឃុំឃាំងរយៈពេលមួយខែ នៅភូមិព្រៃស្នៀង ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ ដោយសារខ្ញុំធ្លាប់ធ្វើជាកងជីវពលការពារភូមិនៅក្នុងរបប លន់ នល់។ ខ្មែរក្រហមបានឱ្យខ្ញុំធ្វើការងារធ្ងន់ធ្ងរ ប៉ុន្តែមិនបានធ្វើទារុណកម្មខ្ញុំទេ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៥ ខ្ញុំបាន*

---

[19] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ លាក់ ជ័យរិទ្ធី ជាមួយ ប្រាក់ ថាវី នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

[20] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03195 បទសម្ភាសន៍ សាន ប៊ុនសុន ជាមួយ ពេជ្រ សុផាត នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

[21] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ លាក់ ជ័យរិទ្ធី ជាមួយ ឡឹក ឆោម នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

[22] វត្តពេជ្រមន្ត្រី ហៅវត្តឧត្តុង្គ ស្ថិតនៅភូមិពោធិវង្ស ឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

*ត្រលប់ធ្វើការងារនៅកងចល័តជាមួយបងប្រុសរបស់ខ្ញុំ នៅភូមិតាណវិញ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហម បានជម្លៀសខ្ញុំទៅនៅស្រុកកៀនស្វាយ ខេត្តកណ្តាល។ នៅទីនោះខ្ញុំធ្វើការងារធ្ងន់ និងលំបាកជាងនៅខេត្តស្វាយរៀង។ ខ្ញុំរស់នៅស្រុកកៀនស្វាយរហូតដល់ឆ្នាំ១៩៧៩។*

*គង់ យូ[23] ភេទស្រី អាយុ៧៦ឆ្នាំ (ក្នុងឆ្នាំ២០០៥) មានស្រុកកំណើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង មានប្រសាសន៍ថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅនៅ ភូមិចំបក់កោង ឃុំតាសួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ នៅទីនោះខ្មែរក្រហម ចាត់តាំងឱ្យខ្ញុំមើលក្មេងៗ ដេរស្លឹកត្នោតសម្រាប់ប្រក់ផ្ទះ រែកដីដាក់ស្រែ និងឱ្យបាយជ្រូក។ ខ្មែរក្រហមចែករបបអាហារឱ្យខ្ញុំតិចតួចប៉ុណ្ណោះ ព្រោះខ្មែរក្រហមចាត់ទុកថាខ្ញុំគឺជាប្រជាជនថ្មី។*

ចំពោះរបបអាហារ ប្រធានភូមិបានបែងចែករបបអង្ករឱ្យពីរកំប៉ុងក្នុងមួយថ្ងៃសម្រាប់មនុស្សប្រាំមួយនាក់។ នៅក្នុងភូមិតាណរ៍ មានសហករណ៍មួយ ដែលប្រជាជននាំគ្នាហៅថា «សហករណ៍ភូមិម្តេញ»។ សហករណ៍នេះ មានទីតាំងស្ថិតនៅផ្ទះរបស់យាយ និន នៅភូមិតាណរ៍ (ខាងត្បូង)។ ខ្មែរក្រហមបានសង់រោងវែងមួយសម្រាប់ប្រជាជននៅក្នុងភូមិតាណរ៍មកហូបអាហាររួមគ្នា។ នៅពេលប្រជាជនឈឺថ្កាត់ម្តងៗ ប្រធានភូមិបានបញ្ជូនអ្នកជំងឺទាំងនេះឱ្យទៅព្យាបាលនៅមន្ទីរពេទ្យឃុំស្វាយតឿ ដែលមានទីតាំងស្ថិតនៅក្នុងភូមិទាហានក្រោម គ្រប់គ្រងដោយប្រធានពេទ្យឈ្មោះមិត្ត សាត និងសមាជិកពេទ្យមិត្ត រី និងមិត្ត ម៉ាឡៃ។ មន្ទីរពេទ្យនេះសម្រាប់ព្យាបាលជំងឺប្រជាជននៅក្នុងឃុំស្វាយតឿទាំងមូលដែលឈឺស្រាល។ ដោយឡែកអ្នកជំងឺឈឺធ្ងន់ ប្រធានមន្ទីរពេទ្យបានបញ្ជូនបន្តដោយសែងតាមអង្រឹងយកទៅព្យាបាលនៅមន្ទីរពេទ្យតំបន់២៣ ស្ថិតនៅក្នុងក្រុងស្វាយរៀង។

*ពេជ្រ សាអ៊ន ភេទស្រី អាយុ៥៦ឆ្នាំ (នៅក្នុងឆ្នាំ២០១០) មានស្រុកកំណើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃរស់នៅភូមិដដែលមានប្រសាសន៍ថា មិត្ត ធន ប្រធានភូមិតាណរ៍ កាចណាស់ និងមិនលើកលែងទោសូម្បីប្រជាជនប្រព្រឹត្តកំហុសបន្តិចបន្តួច។ ប្រជាជនលួចបូតស្រូវក៏ ធន រាយការណ៍ទៅឱ្យគណៈឃុំដែរ។ នៅឆ្នាំ១៩៧៦ កងចល័តនៅភូមិតាណរ៍ ត្រូវបានខ្មែរក្រហមបញ្ជូនឱ្យទៅធ្វើស្រែនៅភូមិវត្តដួលជិតព្រំដែនវៀតណាម ហើយនៅពេលនោះកងចលត័ខ្លះក៏ត្រូវរងការចោទប្រកាន់ថា «មានបំណងរត់ទៅវៀតណាម» ដែរ។*

*សាអ៊ន ត្រូវបានប្រធានភូមិចាត់តាំងទៅស្ទូងស្រែ នៅជិតវត្តដួល ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីព្រំដែនវៀតណាម។ ពេលសម្រាកពីធ្វើស្រែ គាត់បានមកលេងផ្ទះ យាយ ទូច ដែលជាប្រជាជនរស់នៅក្នុងភូមិដែលគាត់ធ្វើការ។ សាអ៊ន ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា បានបំផុសប្រជាជនឱ្យរត់ទៅប្រទេសវៀតណាម រួចហើយរាយការណ៍ប្រាប់ទៅ តាម៉ី គណៈឃុំស្វាយតឿ។ សាអ៊ន ត្រូវបានគណៈឃុំស្វាយតឿ ហៅទៅសួរចម្លើយបីដង។*

---

[23] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ សោម ប៊ុនថន ជាមួយ គង់ យូ នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

*នៅថ្ងៃទី៣បន្ទាប់ពីសួរចម្លើយរួច ក៏មានការប្រកាសឱ្យកងចល័តទៅដឹកព្រែកនៅស្រុករមាសហែក ទើបគាត់បានរួចខ្លួន។ សារ៉ាន បានបន្តថា ខ្មែរក្រហមបានបញ្ជូនកងចល័ត និងកងតាៗ ដែលរស់វែងដីនៅក្នុងភូមិតាណៅឱ្យទៅដឹកព្រែកនៅស្រុករមាសហែក។ កងចល័តនៅពេលនោះមានចំនួនរាប់ពាន់នាក់មកពីភូមិផ្សេងៗ។ កងចល័តត្រូវដឹកព្រែកកាត់តាមភូមិដក់ពរ ភូមិទួលកី ទួលឈើក្រំ រហូតទៅទល់នឹងភូមិហែកសំណាញ់ ដែលមានចម្ងាយរាប់សិបគីឡូម៉ែត្រ។ បន្ទាប់ពីដឹកព្រែកចប់តាមផែនការ ទើបខ្មែរក្រហមអនុញ្ញាតឱ្យប្រជាជនត្រលប់មកធ្វើស្រែនៅក្នុងភូមិវិញ។*

*នៅក្នុងអំឡុងពេលនោះ ការគ្រប់គ្រងនៅក្នុងភូមិកាន់តែតឹងតែងខ្លាំង ជាពិសេសអ្នកដែលរងការចោទថា លួចរបស់របរសមូហភាព។*

*ពៅ សារិន ភេទប្រុស គឺជាគ្រូបង្រៀនអាយុ៥២ឆ្នាំ (ក្នុងឆ្នាំ២០១០) មានស្រុកកំណើតនៅភូមិតាណៅ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃរស់នៅភូមិដដែលមានប្រសាសន៍ថា ពេលគាត់ត្រលប់មកផ្ទះ គាត់បានបូតស្រូវ ពេលនោះឈ្លបខ្មែរក្រហមឃើញក៏ចាប់ខ្លួនគាត់ រួចសរសេរសំបុត្រមួយច្បាប់បញ្ជូនទៅឱ្យគណៈឃុំ តាម៉ី។ តាម៉ី បានយកសំបុត្រនោះញាត់ទៅក្រោមរនូតគ្រែឫស្សី រួចហៅគាត់មកសួរថា មូលហេតុអ្វីបានជាគាត់លួចរបស់សមូហភាព។ បន្ទាប់ពីសួររួច តាម៉ី បានរុញគាត់ទៅនឹងរណ្តៅរួចយកគល់ឫស្សីបម្រុងនឹងវាយពីក្រោយ តែគាត់បានក្រាញ។ ពេលនោះ តាម៉ី ក៏បានដូរចិត្តដោយនិយាយថា «ទុកឱ្យរស់សិន» ទើបគាត់បានរួចខ្លួន។*

**ការស៊ើបរកខ្មាំង**

នៅអំឡុងឆ្នាំ១៩៧៧ វៀតណាមបានវាយចូលមកនៅតាមព្រំដែន ពេលនោះខ្មែរក្រហមបានចាប់ផ្តើមរឹតបន្តឹងកាន់តែខ្លាំង និងតាមស៊ើបរកព័ត៌មានអ្នកធ្លាប់ធ្វើរដ្ឋការ ប្រជាជនដែលចូលដៃជាមួយខ្មាំង និងគ្រួសារដែលមានផែនការរត់ទៅប្រទេសវៀតណាម។

*ពេជ្រ សារ៉ាន បានឱ្យដឹងថា គ្រួសាររបស់ រុន បានរត់គៀសខ្លួនទៅប្រទេសវៀតណាម នៅអំឡុងពេលមានការវាយប្រយុទ្ធរវាងកងទ័ពវៀតណាម និងយោធាខ្មែរក្រហមដំបូង។ ពេលនោះ កូនប្រុសវ័យជំទង់របស់ រុន ម្នាក់ឈ្មោះ សុខ ដែលធ្វើការនៅកងចល័តនៅភូមិទាហានក្រោមមិនបានទៅជាមួយក្រុមគ្រួសារទេ។ ពេលនោះ កងឈ្លបឃុំបានមកចាប់គាត់យកទៅចងនៅក្រោមដើមពោធិ៍ នៅក្នុងភូមិទាហានក្រោមដើម្បីវាយសួរចម្លើយ បន្ទាប់មកក៏យកទៅសម្លាប់ចោល។ ចំណែក ឈុន ដែលត្រូវជាកូនរបស់ តាជា និងយាយម៉ី ដែលធ្វើការនៅកងចល័ត ក៏ត្រូវកងឈ្លបចាប់ដឹកតាមម៉ូតូយកទៅមន្ទីរសន្តិសុខតំបន់ «ឫស្សីសាញ់» ដែរ ប៉ុន្តែ ឈុន តដៃជាមួយកងឈ្លប រួចហើយរត់ឡើងទៅពួននៅលើចុងត្នោត។ ក្រោយមក កងឈ្លបខ្មែរក្រហមបានតាមទាន់ ក៏បាញ់សម្លាប់ចោលនៅទីនោះ។ ដោយឡែកបងប្រុសរបស់ សារ៉ាន ម្នាក់ឈ្មោះ ធើយ ដែលជាអតីតទាហាន លន់ នល់ ត្រូវប្រជាជនក្នុងភូមិរាយការណ៍ប្រាប់ពីប្រវត្តិពិត ប្រាប់គណៈឃុំ តាម៉ី ជាញឹកញាប់។ ក្រោយពេលដែល តាម៉ី ត្រូវបានចាប់ខ្លួន ហើយដាក់គណៈឃុំថ្មីមកជំនួស ធើយ ក៏ត្រូវបានចាប់យកទៅសម្លាប់ដែរ។*

**ការបង្កើតមន្ទីរសន្តិសុខ**

នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមក៏ចាប់ផ្តើមបង្កើតមន្ទីរសន្តិសុខមួយនៅក្នុងភូមិនេះគឺ «មន្ទីរសន្តិសុខតាណាវ៍» ដោយខ្មែរក្រហមបានយកកម្មាភិបាលមកពីស្រុកកំពង់ពោទិ៍មកគ្រប់គ្រង។ មន្ទីរសន្តិសុខនេះ គឺជាអតីតផ្ទះជញ្ជាំងបូកដីមួយខ្នង និងមានដំបូលប្រក់ស្លឹកត្នោតរបស់ប្រជាជនភូមិតាណាវ៍ (ខាងត្បូង) ឈ្មោះ ខុន។ ខ្មែរក្រហមបានប្រើប្រាស់ផ្ទះនេះធ្វើជាកន្លែងសួរចម្លើយ និងជាកន្លែងឃុំឃាំងអ្នកទោស។ អ្នកទោសត្រូវបានឈ្លបខ្មែរក្រហមចាប់យកមកឃុំឃាំងនៅ «មន្ទីរសន្តិសុខតាណាវ៍» រយៈពេលមួយខែមុននឹងយកទៅសម្លាប់នៅរណ្តៅសាកសពរួម។

នៅពេលខ្មែរក្រហមមានជម្លោះជាមួយវៀតណាមកាន់តែខ្លាំង ខ្មែរក្រហមចាប់ផ្តើមចាប់ខ្លួនគណៈឃុំ និងគណៈស្រុកជាបន្តបន្ទាប់ ដោយឡែកប្រធានមន្ទីរសន្តិសុខតាណាវ៍ពីមុនក៏ត្រូវបានចាប់ខ្លួនដែរ រួចខ្មែរក្រហមដាក់កម្មាភិបាលមកពីភូមិភាគនិរតីមកគ្រប់គ្រងជំនួស។ នៅពេលនោះ អ្នកទោសកាន់តែច្រើនឡើងត្រូវបានយកមកសម្លាប់នៅមន្ទីរសន្តិសុខនេះ។ អ្នកទោសភាគច្រើនត្រូវបានយោធាខ្មែរក្រហមចាប់យកមកពីស្រុកចន្ទ្រា និងស្រុកផ្សេងទៀតក្នុងខេត្តស្វាយរៀងនៅពេលមានការវាយប្រយុទ្ធគ្នាជាមួយវៀតណាម។

នៅឆ្នាំ១៩៧៨ ប្រជាជនមួយចំនួនដែលរស់នៅតាមព្រំដែនវៀតណាម ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកមន្ទីរសន្តិសុខតាណាវ៍ដើម្បីឃុំឃាំង សួរចម្លើយ និងសម្លាប់ចោល[24]។ គ្មាននរណាម្នាក់បានឃើញច្បាស់លាស់ថាមានអ្វីកើតឡើងនៅក្នុងបរិវេណមន្ទីរសន្តិសុខនេះទេ ព្រោះខ្មែរក្រហមហាមមិនឱ្យចូលបរិវេណនេះជាដាច់ខាត។ អ្នកទោសដែលបញ្ជូនមកមន្ទីរសន្តិសុខនេះ គឺជាប្រជាជនដែលរស់នៅជិតព្រំដែនវៀតណាម និងមានបំណងរត់ទៅប្រទេសវៀតណាម ហើយប្រជាជនមួយចំនួនទៀតត្រូវបានខ្មែរក្រហមកៀរមកភូមិតាណាវ៍ នៅពេលប្រជាជនទាំងនេះមិនព្រមជម្លៀសទៅតាមការបញ្ជារបស់ខ្លួន។ មន្ទីរសន្តិសុខតាណាវ៍ គឺជាសាខាមួយរបស់មន្ទីរសន្តិសុខឫស្សីសាញ់។[25] មន្ទីរសន្តិសុខតាណាវ៍ មានជនរងគ្រោះចំនួន ២១៧ត្រូវបានសម្លាប់ និងកប់នៅក្នុងរណ្តៅសាកសពរួមចំនួន ៥កន្លែង។ រណ្តៅសាកសពនេះ ត្រូវបានរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាគាស់នៅឆ្នាំ១៩៨២ និងបានប្រមូលអដ្ឋិធាតុជនរងគ្រោះដាក់តម្កល់នៅបូជនីយដ្ឋាន។[26]

---

[24] ទស្សនាវដ្តីស្វែងរកការពិត លេខ៩៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ ១១។

[25] ទស្សនាវដ្តីស្វែងរកការពិត លេខ៩៥ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ ១១៖ មន្ទីរសន្តិសុខឫស្សីសាញ់គឺជាមន្ទីរសន្តិសុខធំជាងគេនៅស្រុកកំពង់ពោទិ៍ ខេត្តស្វាយរៀង។ មន្ទីរសន្តិសុខនេះមានឃុំឃាំងអ្នកទោសភាគច្រើនគឺជាបុរសដែលអង្គការចោទប្រកាន់ថា បានក្បត់នឹងអង្គការ មានគំនិតចង់បំផ្លាញបដិវត្តន៍។ មន្ទីរសន្តិសុខឫស្សីសាញ់ មានមន្ទីរសន្តិសុខតូចៗជាច្រើនទៀតជាចំណុះ ដែលមានតួនាទីសំខាន់ក្នុងការបញ្ជូនអ្នកទោសដែលសួរចម្លើយដឹងថាមានទោសធ្ងន់មកកាន់មន្ទីរសុខឫស្សីសាញ់។ ពេជ្រ សារឿន គឺជាប្រធានក្តោបក្តាប់រួមលើមន្ទីរសន្តិសុខទាំងតូចទាំងធំ និងមានអនុប្រធានឈ្មោះ សារ៉ន (សព្វថ្ងៃរស់នៅស្រុកល្វាឯម ខេត្តកណ្តាល) ហើយសមាជិកពីររូបទៀតគឺ ជួប និង បូ។ ចំណែក មាស ផន គឺជាកម្មាភិបាលកាន់កាប់បញ្ជីឈ្មោះអ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខឫស្សីសាញ់។

[26] ទស្សនាវដ្តីស្វែងរកការពិតលេខ៣០ ខែមិថុនា ឆ្នាំ២០០២, ទំព័រ ១០។

*ប្រាក់ ថាវី[27] បានរៀបរាប់បន្ថែមថា ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមយកទៅកសាងនៅវត្តឫស្សីសាញ់ រយៈពេល៣ខែ ព្រោះឪពុករបស់គាត់ គឺជាអតីតទាហានសង្គមចាស់។ ដូច្នេះម្តាយរបស់គាត់បានយកទ្រព្យសម្បត្តិដែលលាក់ទុកទៅឱ្យអ្នកដែលយកឪពុករបស់គាត់រៀនសូត្រ ទើបបានដោះលែងឪពុករបស់គាត់ត្រលប់មកផ្ទះវិញ។ នៅឆ្នាំ១៩៧៧ ថាវី និងគ្រួសារ រួមជាមួយប្រជាជនជាច្រើនគ្រួសារទៀត បានរត់ភៀសខ្លួនទៅប្រទេសវៀតណាម។ ប្រជាជនមួយចំនួនត្រូវបានខ្មែរក្រហមកៀរត្រលប់មកវិញ និងយកទៅសម្លាប់នៅភូមិតាណរ៍។ ប្រជាជនដែលរត់គេចខ្លួន ត្រូវបានកងទ័ពវៀតណាមនៅខេត្តឡុងអានចាំទទួល។ វៀតណាមបានសង់ជំរំឱ្យជនភៀសខ្លួនខ្មែររស់នៅ និងចែកស្បៀងអាហារឱ្យ។ វៀតណាមក៏បានអនុញ្ញាតឱ្យជនភៀសខ្លួនរកស៊ីកាប់ឧសលក់ឱ្យជនជាតិវៀតណាមដែរ។*

**ការជម្លៀសលើកទីពីរ**

នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមមានជម្លោះប្រដាប់អាវុធជាមួយប្រទេសវៀតណាម និងបានវាយប្រយុទ្ធគ្នានៅតាមព្រំដែន។ អំឡុងពេលនោះ កងទ័ពវៀតណាម បានវាយចូលមកទឹកដីក្នុងខេត្តស្វាយរៀងមួយរយៈខ្លីក៏ដកកងទ័ពត្រលប់ទៅវិញ។ ដោយសារភ័យខ្លាចវៀតណាមវាយចូលមកដល់ក្រុងស្វាយរៀង ទើបខ្មែរក្រហមបានផ្លាស់ប្តូរមន្ទីរធ្វើការរបស់ខ្លួនដែលមានទីតាំងស្ថិតនៅសង្កាត់ពោធិ៍តាហោ (ខាងកើតក្រុងស្វាយរៀង) ទៅនៅក្នុងភូមិក្តីស្លា ឃុំស្វាយយា និងឃុំផ្សេងទៀតក្នុង ស្រុកមានជ័យថ្មី ( សព្វថ្ងៃស្រុកស្វាយជ្រុំ ខាងលិចក្រុងស្វាយរៀង) តំបន់២៣ ដែលស្ថិតនៅឆ្ងាយពីព្រំដែនវៀតណាម។ ពេលនោះ ខ្មែរក្រហមបានក៏ចាប់ផ្តើមជម្លៀសប្រជាជននៅភូមិតាណរ៍លើកទីពីរទៅទិសខាងលិចសំដៅទៅនៅស្រុកមានជ័យថ្មី និងខេត្តព្រៃវែង បន្ទាប់មកទើបខ្មែរក្រហមយកឡានមកដឹកបន្តទៅដាក់នៅស្រុកកៀនស្វាយ ខេត្តកណ្តាល និងតំបន់ផ្សេងៗទៀត។ ប្រជាជនក្នុងភូមិតារណ៍ភាគច្រើន ត្រូវបានខ្មែរក្រហមបែងចែកឱ្យទៅរស់នៅតាមផ្ទះប្រជាជននៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល។ ប្រជាជនទាំងនេះត្រូវចាត់តាំងឱ្យប្រមូលកំប្លោក ស្មូងស្រូវ និងក្តួរស្រែ ចំណែករបបអាហារសម្រាប់អ្នកជម្លៀសមកថ្មីទាំងនេះមិនគ្រប់គ្រាន់ឡើយ។ ទោះបីយ៉ាងណា ខ្មែរក្រហមនៅកៀនស្វាយ មិនសូវតឹងរឹង និងចាប់កំហុសប្រជាជនដែលជម្លៀសមកថ្មីទាំងនេះទេ។ ប្រជាជននៅភូមិតាណរ៍បានរស់នៅស្រុកកៀនស្វាយ រហូតដល់វៀតណាមចូលមកប្រទេសកម្ពុជានៅខែមករា ឆ្នាំ១៩៧៩ ទើបត្រលប់មកស្រុកកំណើតវិញ។

*ញ៉ែម ផល[28] ភេទប្រុស អាយុ៤០ឆ្នាំ កើតនៅភូមិតាណរ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ហើយសព្វថ្ងៃរស់នៅភូមិដដែល បានរៀបរាប់ថា ខ្ញុំរស់នៅភូមិកំណើត ហើយខ្មែរក្រហមប្រើឱ្យលើកភ្លឺស្រែ និងហូបបាយនៅតាមផ្ទះរៀងខ្លួន។ បន្ទាប់មក ទើបខ្មែរក្រហមជម្លៀសខ្ញុំឱ្យទៅរស់នៅ*

[27] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ លាក់ ជ័យរិទ្ធី ជាមួយ ប្រាក់ ថាវី នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

[28] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ លាក់ ជ័យរិទ្ធី ជាមួយ ប្រាក់ ថាវី នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

*វត្តឡ ស្ថិតនៅក្នុងភូមិស្វាយតឿ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ នៅទីនោះ ខ្មែរក្រហមប្រើខ្ញុំឱ្យឃ្វាលគោពីម៉ោង ៦ព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ទើបបានឈប់សម្រាក ហើយទទួលបានរបបបាយមួយវែក។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំឱ្យទៅរស់នៅស្រុកកៀនស្វាយ ខេត្តកណ្ដាល ដោយចាត់តាំងខ្ញុំឱ្យលើកភ្លឺស្រែ។ ក្រៅពីការងារលើកទំនប់ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យឃ្វាលគោជាច្រើនក្បាលទៀត ហើយប្រសិនខ្ញុំធ្វើឱ្យបាត់គោ ខ្មែរក្រហមនឹងយកខ្ញុំទៅសម្លាប់ចោលមិនខាន។ ចំណែករបបអាហារវិញ ខ្ញុំទទួលបានបបរមួយវែកក្នុងមួយពេល។ ប្រសិនបើនរណាម្នាក់ចាប់កង្កែបមកហូប ហើយឈ្លបឃើញ គឺឈ្លបយកអ្នកនោះទៅវាយចោលមិនខាន។ ខ្ញុំរស់នៅស្រុកកៀនស្វាយរហូតដល់កងទ័ពវៀតណាមវាយចូលមក ទើបខ្ញុំត្រលប់មកស្រុកកំណើតវិញ។*

*សោម សុខុន[29] ភេទប្រុស អាយុ ៦៥ឆ្នាំ (ក្នុងឆ្នាំ២០០៥) កើតនៅភូមិតាណែ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង និងសព្វថ្ងៃរស់នៅភូមិដដែលមានប្រសាសន៍ថា នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសខ្ញុំពីឃុំស្វាយតឿឱ្យទៅរស់នៅឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ នៅទីនោះខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យកាប់ដើមត្រែង បាចទឹកដាក់សំណាប និងស្ទូងស្រូវ ដោយចែកបបរលាយដើមចេកឱ្យខ្ញុំហូប។ ខ្ញុំបានរស់នៅជាមួយប្រពន្ធ ចំណែកកូនៗរបស់ខ្ញុំ ខ្មែរក្រហមបានបំបែកឱ្យទៅធ្វើការ និងរស់នៅកងផ្សេង។ ក្រោយមកខ្មែរក្រហមបានបញ្ជូនខ្ញុំឱ្យមកធ្វើការងារនៅម្ដុំអ្នកលឿង ហើយប្រហែលម៉ោង ៩ព្រឹក ខ្ញុំក៏ឃើញកងទ័ពវៀតណាមចូលមកដល់ និងប្រកាសឱ្យខ្ញុំវិលត្រលប់ទៅស្រុកកំណើតវិញ។*

*ម៉ី សុផាន[30] ភេទស្រី អាយុ ៥៣ឆ្នាំ (ក្នុងឆ្នាំ២០០៥) រស់នៅភូមិតាណែ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង បានមានប្រសាសន៍ថា ខ្មែរក្រហមបានជម្លៀសខ្ញុំពីភូមិតាណែទៅនៅវត្តឧត្តុង្គ[31] (វត្តពេជ្រមន្ត្រី) មួយរយៈទើបផ្លាស់ខ្ញុំមករស់នៅវត្តឡ[32] វិញ។ នៅទីនោះខ្មែរក្រហមបានប្រើខ្ញុំឱ្យដកស្ទូងពីម៉ោង ៧ព្រឹក ដល់ម៉ោង ១២ថ្ងៃត្រង់ និងពីម៉ោង ១រសៀល ដល់ម៉ោង ៥ល្ងាច ដោយឱ្យហូបបបរ និងស្នាក់នៅក្នុងរោង។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅបឹងរ៉ៃ[33] បានមួយរយៈខ្លីប៉ុណ្ណោះ រួចហើយទើបបញ្ជូនបន្តទៅរស់នៅស្រុកកៀនស្វាយ ខេត្តកណ្ដាល។ នៅទីនោះខ្មែរក្រហមបានចាត់តាំងខ្ញុំឱ្យជីកប្រឡាយ។ ចំណែកបងប្រុសរបស់ខ្ញុំម្នាក់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់។ គាត់រស់នៅស្រុកកៀនស្វាយរហូតដល់របបខ្មែរក្រហមដួលរលំ។*

សន្និដ្ឋាន

[29] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ សោម ប៊ុនថន ជាមួយ សោម សុខុន នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៥។

[30] មជ្ឈមណ្ឌលឯកសារកម្ពុជា, គម្រោងផ្សព្វផ្សាយ, ឯកសារS03212 បទសម្ភាសន៍ កែវ ដួង ជាមួយ ម៉ី ផាន នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៥។

[31] វត្តពេជ្រមន្ត្រី ហៅវត្តឧត្តុង្គ ស្ថិតនៅភូមិពោធិវង្ស ឃុំប្រសូត្រ ស្រុកស្វាយទាប ខេត្តស្វាយរៀង។

[32] វត្តឡ ស្ថិតនៅភូមិស្វាយតឿ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។

[33] បឹងរ៉ៃ ស្ថិតនៅឃុំក្រោគោ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។

ក្រោយរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជននៅក្នុងភូមិតាណេរ៍ដែលខ្មែរក្រហមជម្លៀសឱ្យទៅរស់នៅស្រុកកៀនស្វាយ ខេត្តកណ្តាល និងតំបន់ផ្សេងៗបានវិលត្រលប់មកស្រុកកំណើតរបស់ខ្លួនវិញ។ ប្រជាជនមួយចំនួនបានបាត់បង់សមាជិកគ្រួសាររបស់ខ្លួនដោយសារការអត់អាហារ ការឈឺគ្មានថ្នាំព្យាបាល ការចោទប្រកាន់ថាជាខ្មាំងប្រឆាំងនឹងអង្គការបដិវត្តន៍ និងការចាប់ខ្លួនពេលរត់គេចទៅប្រទេសវៀតណាម។ រហូតដល់បច្ចុប្បន្ន ប្រជាជនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមក្នុងភូមិតាណេរ៍នៅរស់រានមានជីវិតតិចតួចប៉ុណ្ណោះ ហើយអ្នកទាំងនេះនៅតែរៀបរាប់ពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងភូមិ និងផលប៉ះពាល់នៃសង្គ្រាមដែលបណ្តាលឱ្យមានការសម្លាប់។






# ឯកសារយោង

- ទស្សនាវដ្ដីស្វែងរកការពិត។
- របាយការណ៍ផែនទីរណ្ដៅសាកសព ឆ្នាំ១៩៩៥ ។
- គម្រោងផ្សព្វផ្សាយអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០៥។
- របាយការណ៍វិភាគអំពីសកម្មភាពយោធា នៅក្នុងខេត្តស្វាយរៀង ដែលចេញផ្សាយដោយស៊ីអាយអេ។
- សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

**អ្នកផ្ដល់សម្ភាសន៍៖**

១) កែវ សារ៉ន អតីតទាហាន លន់ នល់ និងអតីតយុទ្ធជនខ្មែរក្រហម អាយុ ៥៥ឆ្នាំ នៅឆ្នាំ២០១០ នៅភូមិតាណរ៍ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង ឆ្នាំ២០១០។

២) សោម សុខ អតីតទាហាន លន់ នល់ អាយុ៥៦ឆ្នាំ នៅឆ្នាំ២០១០ រស់នៅភូមិតាណរ៍ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

៣) រាជ សារ៉ាត ជាប្រជាជន អាយុ៥៩ឆ្នាំ នៅឆ្នាំ២០១០ នៅភូមិតាណរ៍ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

៤) នាង សារិន អតីតកងចល័ត អាយុឆ្នាំ៥០ នៅឆ្នាំ២០១០ គឺជាគ្រូបង្រៀន រស់នៅភូមិតាណរ៍ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

៥) ពេជ្រ សារ៉ាន អតតីកងចល័ត អាយុ៥៤ឆ្នាំ នៅឆ្នាំ២០១០ រស់នៅភូមិតាណរ៍ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង។

៦) សោម សាខន អតីតទាហាន លន់ នល់ អាយុ៦៨ឆ្នាំ នៅឆ្នាំ២០១០ គឺមេភូមិតាដោរ៍ រស់នៅភូមិតាដោរ៍ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

**កម្រងសំណួរស្រាវជ្រាវ**

១. សំណួរស្រាវជ្រាវ ៖ ស្ថានភាពរស់នៅរបស់ប្រជាជនក្នុងភូមិតាណរ៍ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ ដល់របបខ្មែរក្រហមគ្រប់គ្រង

២. វត្ថុបំណងនៃការស្រាវជ្រាវ ៖

- ស្ថានភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិតាណរ៍អំឡុងរដ្ឋប្រហារឆ្នាំ១៩៧០
- ការជម្លៀសប្រជាជនរស់នៅក្នុងភូមិតាណរ៍ក្នុងអំឡុងពេលខ្មែរក្រហមចូលមកគ្រប់គ្រង
- រចនាសម្ព័នគ្រប់គ្រងរបស់ខ្មែរក្រហមនៅក្នុងភូមិភូមិតាណរ៍

៣. សំណួរគោល ៖

- ការងារ
- ជំនឿ ប្រពៃណី សាសនា
- ការអប់រំ
- សេវាព្យាបាល
- ការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងភូមិ

៤. សំណួរលម្អិត

- ភូមិសាស្ត្រភូមិតាណរ៍
- មុខរបររបស់ប្រជាជនៅក្នុងភូមិ
- ការចូលរួមរបស់ប្រជាជននៅក្នុងសង្គម
- ការជម្លៀសប្រជាជន
- ការងារប្រចាំថ្ងៃ
- របបអាហារ
- ការបង្កើតមន្ទីរសន្តិសុខ
- ការចោទប្រកាន់និងសម្លាប់